# ស្ថានភាពអតិផរណានៅខែតុលា ឆ្នាំ២០១៦

*******

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែតុលា ឆ្នាំ២០១៦ បានកើនឡើង **០,៤%** ធៀបនឹងខែមុននិងបានកើនឡើង **៣,៤%** ធៀបនឹង១២ខែកន្លងទៅ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់មានការកើនឡើងគួរកត់សម្គាល់ធៀបនឹងខែកញ្ញាកន្លងទៅនោះមានដូចជា សន្ទស្សន៍ថ្លៃម្ហូបអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង បានកើនឡើង ០,៤% ដោយសារកំណើនថ្លៃសាច់គោ ថ្លៃសាច់មាន់និងថ្លៃត្រីស្រស់។ សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ បានកើនឡើង ០,៣% ក្នុងនោះថ្លៃស្រាកើនឡើង ០,៧% និងថ្លៃថ្នាំជក់កើនឡើង ០,៣%, សន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានកើនឡើង ០,៨% ដោយសារកំណើនថ្លៃប្រេងសាំងធម្មតា ១,៩% និងកំណើនថ្លៃប្រេងម៉ាស៊ូត ១,១%។ ប៉ុន្តែសន្ទស្សន៍ថ្លៃនៃក្រុមទំនិញដទៃទៀតក៏មានការថយចុះឬស្ថិតនៅនឹងផងដែរ មានដូចជាសន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈ, សន្ទស្សន៍ថ្លៃគ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់។ល។

បើធៀបនឹង១២ខែមុន សន្ទស្សន៍ថ្លៃក្រុមទំនិញមួយចំនួនបានកើនឡើង ជាពិសេសសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង បានកើនឡើង ៥,៩% ក្នុងនោះថ្លៃសាច់គោកើនឡើង ១០,៤% និងត្រីស្រស់បានកើនឡើង ១១,២% និងសន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ បានកើនឡើង ៩,២%។ ផ្ទុយទៅវិញ សន្ទស្សន៍ថ្លៃការដឹកជញ្ជូនបានថយចុះ ៥,០% និងសន្ទស្សន៍ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈបានថយចុះ ០,២%។

តាមការធ្វើចំណោលគិតដល់ត្រឹមខែធ្នូ ឆ្នាំ២០១៦នេះ អតិផរណាប្រចាំឆ្នាំ(year on year)អាចមានអត្រា ៣,៦% ឬអតិផរណាមធ្យមប្រចាំឆ្នាំ(year average)អាចមានអត្រា ៣,០%។

តារាង ១÷ ការប្រែប្រួលសន្ទស្សន៍ថ្លៃទាំង១២ ក្រុម មានដូចខាងក្រោម÷

| | ធៀបខែមុន | ធៀប១២ខែមុន |
|---|---|---|
| **មុខទំនិញគ្រប់មុខ** | **0.4** | **3.4** |
| ១-អាហារនិងភេសជ:មិនមានជាតិស្រវឹង | 0.4 | 5.9 |
| ២-ភេសជ:មានជាតិស្រវឹងនិងថាំជក់ | 0.3 | 9.2 |
| ៣-សម្លៀកបំពាក់និងស្បែកជើង | 0.1 | 2.6 |
| ៤-ផះសំបែង ទឹក អគិសនី ឧស័ន និងឥនន:ដទៃទៀត | -0.5 | -0.2 |
| ៥-គ្រឿងសង្ហារឹម សមារៈប្រើប្រាស់ និងការថែទាំ | -0.2 | 2.4 |
| ៦-សុខាភិបាល | 0.3 | 2.6 |
| ៧-ការដឹកជពាន | 0.8 | -5.0 |
| ៨-គមនាគមន៍ | -0.1 | -0.5 |
| ៩-ការកំសាន និងវប្បធម៌ | 0.7 | 3.8 |
| ១០-ការសិក្សា | 0.0 | 0.0 |
| ១១-ភោជនីយដាន | 1.1 | 2.3 |
| ១២-ទំនិញ និងសេវាកមផេ្សងៗ | -0.2 | 2.1 |

| តារាង ២÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ (%) | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ២០១៦ | | | | | |
| | ធៀបខែមុន | | | ធៀបនឹងឆ្នាំមុន | | |
| | សីហា | កញ្ញា | តុលា | សីហា | កញ្ញា | តុលា |
| អង្ករ | 0.5 | 0.2 | -0.2 | 3.2 | 2.8 | 2.5 |
| សាច់គោ | 0.8 | 0.3 | 0.2 | 11.2 | 10.8 | 10.4 |
| សាច់មាន់ | 0.5 | 0.6 | 0.9 | 6.2 | 6.5 | 7.8 |
| សាច់ទា | 0.1 | 0.6 | -0.2 | 0.7 | 1.2 | 1.1 |
| សាច់ជ្រូក | 0.5 | 0.1 | -0.2 | 3.9 | 3.8 | 3.9 |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | 0.2 | 0.9 | 0.7 | 9.0 | 9.2 | 10.7 |
| ក្នុងនោះត្រីស្រស់ | 0.1 | 1.2 | 0.7 | 8.8 | 9.1 | 11.2 |
| ផ្លែឈើ | -0.1 | 0.9 | 0.6 | 4.9 | 4.4 | 5.5 |
| ផ្លែឈើស្រស់ | 0.0 | 1.1 | 0.8 | 4.2 | 3.8 | 5.1 |
| បន្លែ | 0.6 | 0 .8 | 2.0 | 6.7 | 6.1 | 9.0 |
| បន្លែជាស្លឹក | 0.7 | 0.1 | 3.4 | 1.2 | 0.8 | 5.5 |
| បន្លែជាផ្លែ | 1.1 | 1.6 | 1.0 | 16.5 | 14.8 | 18.3 |

## ការប្រែប្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ (ថ្លៃមូលដ្ឋានឆ្នាំ ២០០៦)




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

តារាង៣÷ អតិផរណាប្រចាំឆ្នាំ (ជាភាគរយ)

| ប្រទេស | ២០១៥ | ២០១៦ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា |
| ប្រទេសកម្ពុជា | 2.8 | 3.05 | 2.31 | 2.03 | 2.80 | 3.09 | 3.25 | 3.04 | 2.93 | 3.0 | 3.4 |
| ប្រទេសវៀតណាម | 0.6 | 0.80 | 1.27 | 1.69 | 1.89 | 2.28 | 2.4 | 2.39 | 2.57 | 3.34 | 4.09 |
| ប្រទេសថៃ | -0.85 | -0.53 | -0.50 | -0.46 | 0.07 | 0.46 | 0.38 | 0.10 | 0.29 | 0.38 | 0.34 |
| ប្រទេសម៉ាឡេស៊ី | 2.7 | 3.53 | 4.19 | 2.61 | 2.14 | 2.05 | 1.59 | 1.05 | 1.49 | 1.50 | 1.40 |
| ប្រទេសឥណ្ឌូនេស៊ី | 3.35 | 4.14 | 4.42 | 4.45 | 3.60 | 3.33 | 3.45 | 3.21 | 2.79 | 3.07 | 3.31 |
| ប្រទេសហ្វីលីពីន | 1.5 | 1.35 | 0.92 | 1.13 | 1.10 | 1.56 | 1.91 | 1.91 | 1.83 | 2.26 | 2.3 |
| ប្រទេសចិន | 1.6 | 1.8 | 2.3 | 2.3 | 2.3 | 2.0 | 1.9 | 1.8 | 1.3 | 1.9 | 2.1 |
| ប្រទេសកូរ៉េខាងត្បូង | 1.3 | 0.79 | 1.24 | 0.97 | 1.01 | 0.78 | 0.79 | 0.75 | 0.42 | 1.21 | 1.3 |
| ប្រទេសជប៉ុន | 0.2 | 0.0 | 0.3 | -0.1 | -0.3 | -0.4 | -0.4 | -0.4 | -0.5 | -0.5 | 0.1 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

### <u>កំណត់សម្គាល់</u>

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

*រៀបចំនិងធ្វើចំណោលដោយ*

*នាយដ្ឋានស្ថិតិ*

*អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ*

*ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*